**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ០៩០៤ ព.ណ.ករ

ថ្ងៃ ... ខែ ពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០២១

# សេចក្តីជូនដំណឹង

ក្នុងនាមគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា៖ កម្ពុជានឹងបន្តចូលរួមពិព័រណ៍នាំចូលអន្តរជាតិចិន លើកទីបួន "The 4th China International Import Exposition (CIIE)" ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី០៥-១០ ខែវិច្ឆិកា ឆ្នាំ២០២១ នៅទីក្រុងសៀងហៃ សាធារណរដ្ឋប្រជាមានិតចិន។

ក្នុងព្រឹត្តិការណ៍ពាណិជ្ជកម្មនេះ កម្ពុជានឹងរៀបចំចូលរួមពីចម្ងាយ (Online) ដើម្បីផ្សព្វផ្សាយផលិតផល និងសេវាតាមប្រព័ន្ធអនឡាញជាអន្តរជាតិ និងមានការចាត់បញ្ជូនក្រុមហ៊ុនកម្ពុជាដែលមានសាខា ឬតំណាងចែកចាយផលិតផល និងសេវានៅប្រទេសចិនស្រាប់ទៅចូលរួមដោយផ្ទាល់ដែលមានស្តង់នៅក្នុងតំបន់ពាណិជ្ជកម្ម ដើម្បីស្វែងរកទីផ្សារសម្រាប់ផលិតផលកម្ពុជានិងផ្សព្វផ្សាយអំពីឱកាសវិនិយោគ និងអូសទាញវិនិយោគិនបរទេសឱ្យមកបណ្តាក់ទុនវិនិយោគនៅកម្ពុជា។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងពាណិជ្ជកម្ម សូមអញ្ជើញក្រុមហ៊ុនឯកជនដែលធ្វើធុរកិច្ចនៅកម្ពុជា ហើយមានសាខា ឬតំណាងចែកចាយនៅប្រទេសចិនស្រាប់ និងមានបំណងចូលរួមពិព័រណ៍នាំចូលអន្តរជាតិចិន លើកទីបួន "The 4th China International Import Exposition (CIIE)" ឬមានគម្រោងស្វែងរកដៃគូវិនិយោគ ឬត្រូវចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាជាមួយបណ្តាប្រទេសដែលបានចូលរួម មេត្តាប្រញាប់មកបំពេញបែបបទ និងផ្ញើគម្រោងរបស់ខ្លួនមកនាយកដ្ឋានកិច្ចការពិព័រណ៍ អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ឱ្យបានមុនថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២១ ជាកំណត់ដើម្បីក្រសួងធ្វើការសម្របសម្រួលជូន។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមក នាយកដ្ឋានកិច្ចការពិព័រណ៍ អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម តាមអាសយដ្ឋាន៖ ដីឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ទូរស័ព្ទទំនាក់ទំនង៖ ០៨៦ ៣៣៣ ៩៣៣ ឬ ០៧៨ ៧៣៧ ៧៨៧ ឬ ០១៧ ៧៥៩ ៥៦៧
០៩៥ ៩២៩ ១៩២ ឬ ០១៧ ៥៥៩ ២៧៧ ឬ ០១៧ ៤៩៥ ០៩១

អាសយដ្ឋានអ៊ីម៉ែល៖ som_pitou@yahoo.com ឬ nemoeang@gmail.com ឬ vannameass@yahoo.com
saraysin@yahoo.com ឬ vitholt@yahoo.com ឬ kdi_mpp@yahoo.com

សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម